# ស្ថានទូតអូស្ត្រាលី

## រាជធានីភ្នំពេញ

## សេចក្តីប្រកាសពត៌មាន

## ការពង្រឹងការលូតលាស់សេដ្ឋកិច្ច និង អភិវឌ្ឍន៍វិសយ័ឯកជននៅតំបន់អាស៊ីអាគ្នេយ៍

នៅថ្ងៃទី១៨ ខែ តុលា ឆ្នាំ២០១៣ ទីភ្នាក់ងារអូស្ត្រាលី ដើម្បីអភិវឌ្ឍន៍ អន្តរជាតិ បាន ធ្វើសិក្ខាសាលាដើម្បី ចែករំលែកនូវការរកឃើញ និងមេរៀនបទពិសោធន៍ផ្សេងៗពីមូលនិធិសហគ្រាសឯកជននៅសណ្ឋាគារកាំបូឌីយ៉ាណានៃរាជធានីភ្នំពេញ។ សិក្ខាសាលានេះ មានការចូលរួម ពីបណ្តា មន្ត្រីរាជរដ្ឋាភិបាល ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ និងបណ្តាក្រុមហ៊ុនឯកជននានា។

លោក **ប៉ូល ឃីអូស** ប្រធានទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិប្រចាំកម្ពុជា បានចូលរួមបើកសិក្ខាសាលាជាផ្លូវការ ។ លោក **ប៉ូល ឃីអូស** បានមានប្រសាសន៍ក្នុងពិធីបើកថា "ការអភិវឌ្ឍន៍និងការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព នៅកម្ពុជាមិនអាចសំរេចបានទេ នៅពេលដែលអវត្តមានការលូតលាស់សេដ្ឋកិច្ចដែលដឹកនាំដោយវិស័យឯកជន" ។ តាមរយៈកម្មវិធីអភិវឌ្ឍន៍របស់យើង រដ្ឋាភិបាលអូស្ត្រាលី កំពុងធ្វើភាពជាដៃគូជាមួយវិសយ័ឯកជន ដើម្បីធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជារាប់ពាន់នាក់។

នៅចន្លោះឆ្នាំ២០០៧ ដល់ ឆ្នាំ២០១៣ ក្រុមហ៊ុនពាណិជកម្មចំនួន៧ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍បានប្រើប្រាស់ថវិកាអស់ចំនួន ៣,៦៣លានដុល្លារអូស្ត្រាលី ពីទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដើម្បីបង្កើតឱកាសការងារ និងធ្វើអោយប្រសើរឡើងនូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសំរាប់ប្រជាជនជាង ៧៤ ០០០ រស់នៅជនបទទូទាំងតំបន់។

វិសយ័ឯកជននូវកម្ពុជា ជាដៃគូដ៏សំខាន់នៅក្នុងកម្មវិធី និងក្រុមហ៊ុននៅកម្ពុជាចំនួន ៤ បានទទួលការគាំទ្រប្រកបដោយជោគជ័យ ពីមូលនិធិសហគ្រាសឯកជនថវិកាចំនួន ២,៧លានដុល្លារអូស្ត្រាលី សំរាប់ដំណោះស្រាយដែលប្រកបដោយការឆ្នៃប្រឌិតដើម្បីការលូតលាស់សេដ្ឋកិច្ច។

No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

វីង (WING) គឺជាឧទាហរណ៍មួយនៃពាណិជកម្មនៅកម្ពុជា ដែលរីកចំរើនដោយសារការគាំទ្រពីមូលនិធិសហគ្រាសឯកជន ចាប់តាំងពីឆ្នាំ២០០៨។ វីងបានធ្វើឲ្យមានការវិវត្តន៍នូវភាពងាយស្រួលក្នុងការបង់ថវិកាប្រកបដោយសុវត្ថិភាព សំរាប់ពាណិជកម្មខ្នាតតូច ដែលដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍ប្រទេស។ មូលនិធិសហគ្រាសឯកជនក៏បានគាំទ្រផងដែរមាដា (MEADA) រ៉ាប់រងដើម្បីផ្តល់ការធានារ៉ាប់រ៉ងទៅដល់អ្នកខ្ចីមីក្រូហិរញ្ញប្បទាន ច្រើនជាង ១៤ ០០០ នៅក្នុងប្រទេសកម្ពុជា។ វិទ្យាស្ថាន ប្រៃហូប (Bright Hope Institute) បានពង្រីកមជ្ឈមណ្ឌលអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងខេត្តកំពង់ឆ្នាំង ហើយពពុក អាឡាម (Pupuk Alam) បានធ្វើការអភិវឌ្ឍន៍នុយសំរាប់ចាប់សត្វល្អិតចោះផ្លែឈើ ដើម្បីកាត់បន្ថយការបាត់បង់ផលដំណាំ។

*សំរាប់ពត៌មានបន្ថែមសូមទាក់ទង:*

លោក **ប៉ូល ឃីរូស** ប្រធានទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិប្រចាំកម្ពុជា

***ស្ថានទូតអូស្ត្រាលី ភ្នំពេញ***

*ទូរស័ព្ទលេខ: ០២៣ ២១៣ ៤៧០*

*ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០១៣*